អគ្គនាយកដ្ឋានរដ្ឋបាល
ក្រុមការងារព័ត៌មានវិទ្យា

ORIGINAL
COPY

# កិច្ចព្រមព្រៀង

រវាង

រដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

និង

រដ្ឋាភិបាល នៃ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ស្តីពី

ការដឹកជញ្ជូនផ្លូវគោក

# AGREEMENT

Between

THE GOVERNMENT OF THE KINGDOM OF CAMBODIA

AND

THE GOVERNMENT OF LAO PEOPLE'S DEMOCRATIC REPUBLIC

ON

ROAD TRANSPORTATION

# កិច្ចព្រមព្រៀង

រវាង

# រដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

និង

# រដ្ឋាភិបាល នៃ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ស្តីពី

# ការដឹកជញ្ជូនតាមផ្លូវគោក

រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាល នៃ សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិត ឡាវ ហៅកាត់ថា " ភាគីចុះហត្ថលេខា "

-ក្នុងគោលបំណងពង្រឹងទំនាក់ទំនង រវាងប្រជាជនទាំងពីរប្រទេស ដោយឈរលើមូលដ្ឋាន ស្មើភាព បូរណភាព អធិបតេយ្យភាព និង មានផលប្រយោជន៍ទាំងសងខាង

-ក្នុងគោលបំណងសំរួលការដឹកជញ្ជូនទំនិញអ្នកដំណើរ(រួមទាំងអ្នកទេសចរណ៍)តាមផ្លូវគោក រវាង ប្រទេសទាំងពីរ

## បានព្រមព្រៀងគ្នាដូចខាងក្រោម :

## ប្រការ ១

## បញ្ញត្តិទូទៅ

១- តាមកិច្ចព្រមព្រៀងនេះ ភាគីចុះហត្ថលេខា យល់ព្រមអនុវត្តការដឹកជញ្ជូនទំនិញ អ្នកដំណើរ ( រួមទាំងអ្នក ទេសចរណ៍ ) តាមផ្លូវគោកជាទ្វេភាគី ទៅមករវាងប្រទេសទាំងពីរ តាមច្រកទ្វារព្រំដែនដែលបើក និង យល់ព្រមដោយភាគីទាំងពីរ ។

២- ភាគីចុះហត្ថលេខាមានសិទ្ធ និង កាលានុវត្តភាពស្មើគ្នា នៅក្នុងការអនុវត្តការដឹកជញ្ជូនទំនិញ អ្នកដំណើរ ( រួមទាំងអ្នកទេសចរណ៍ ) តាមផ្លូវគោកជាទ្វេភាគី ទៅមករវាងប្រទេសទាំងពីរ ។

៣- ចំពោះបញ្ហាផ្សេងទៀត ដែលទាក់ទងដល់ការដឹកជញ្ជូនរវាងប្រទេសទាំងពីរដូចជា ការចាត់ចែង និង របបដឹកជញ្ជូន- ការកំណត់ផ្លូវដឹកជញ្ជូន- ការផ្ញើទទួលទំនិញ-ការស្តុកទំនិញ- កំរៃសេវាកម្មដឹកជញ្ជូន និង ចំណាយផ្សេងៗ ត្រូវមានការឯកភាពពីអាជ្ញាធរមានសមត្ថកិច្ច នៃភាគីចុះហត្ថលេខាទាំងពីរ ។

# ប្រការ ២

## និយមន័យ

ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ៖

១-ពាក្យថា " ទឹកដី " គឺទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា និង របស់ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិត ឡាវ

២-ពាក្យថា " អាជ្ញាធរមានសមត្ថកិច្ច" គឺ :

- ខាងភាគីកម្ពុជា គឺក្រសួងសាធារណការ និង ដឹកជញ្ជូន ឬ អង្គភាពណាមួយដែលក្រសួងនេះបានប្រគល់សិទ្ធអោយ ។

- ខាងភាគីឡាវគឺក្រសួងគមនាគមន៍ដឹកជញ្ជូន ប្រៃសណីយ៍ និង សំណង់ ឬ អង្គភាពណាមួយដែលក្រសួងនេះប្រគល់សិទ្ធិអោយ ។

៣-ពាក្យថា " អ្នកដឹកជញ្ជូន " គឺជារូបវន្តបុគ្គល ឬ និតិបុគ្គល ដែលមានអាស័យដ្ឋាន នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ( ហៅកាត់ថាប្រទេសកម្ពុជា ) ឬ នៅលើទឹកដី នៃ សាធារណរដ្ឋ ប្រជាធិបតេយ្យ ប្រជាមានិតឡាវ (ហៅកាត់ថាប្រទេសឡាវ) និង បានទទួលការអនុញ្ញាតិតាមផ្លូវច្បាប់អោយប្រកបអាជីវកម្មដឹកជញ្ជូនអ្នកដំណើរ (រួមទាំងអ្នកទេសចរណ៍ ) និង ដឹកទំនិញតាមផ្លូវគោក ។

៤-ពាក្យថា " រថយន្តដឹកជញ្ជូន " គឺមានរថយន្តដឹកជញ្ជូនទំនិញ និង រថយន្តដឹកជញ្ជូនអ្នកដំណើរ (រួមទាំងរថយន្ត ដឹកជញ្ជូនទេសចរណ៍ )

៥-ពាក្យថា " រថយន្តដឹកជញ្ជូនអ្នកដំណើរ " គឺរថយន្តដឹកជញ្ជូនផ្លូវគោក ដែលមានលក្ខណៈដូចខាងក្រោម:

ក- ផលិត ឬ កែឆ្នៃសំរាប់ដឹកជញ្ជូនអ្នកដំណើរតាមផ្លូវគោក

ខ- មានចំនួនកៅអីចាប់ពី ៨ប់ ឡើងទៅ ដោយគិតទាំងអ្នកបើរបរ

គ- បានចុះបញ្ជី នៅក្នុងទឹកដី នៃភាគីម្ខាងដែលបានចុះហត្ថលេខា និង ជាកម្មសិទ្ធរបស់អ្នកដឹកជញ្ជូន ដែលមានការអនុញ្ញាតិត្រឹមត្រូវតាមផ្លូវច្បាប់អោយដឹកអ្នកដំណើរ ( រួមទាំងអ្នកទេសចរណ៍ ) ។

៦-ពាក្យថា " រថយន្តដឹកជញ្ជូនគ្មានកំរៃ " គឺជារថយន្តដឹកជញ្ជូនអ្នកដំណើរតាមផ្លូវគោក ដែលមានលក្ខណៈដូចខាងក្រោម :

ក-ផលិតសំរាប់ដឹកជញ្ជូនមនុស្សតាមផ្លូវគោក

ខ-មានចំនួនកៅអីចាប់ពី ប្រាំបួន ចុះក្រោមដោយគិតទាំងកៅអីអ្នកបើកបរផង

គ-បានចុះបញ្ជីនៅក្នុងទឹកដីនៃភាគីចុះហត្ថលេខាណាមួយ

ឃ-ធ្វើចរាចរដែលមិនមែនជាសកម្មភាពសេវាដឹកជញ្ជូនយកកំរៃឡើយ ។

៧-ពាក្យថា " រថយន្តដឹកជញ្ជូនទំនិញ " គឺជារថយន្តដឹកជញ្ជូនតាមផ្លូវគោក ដែលមានលក្ខណៈ ដូចខាង ក្រោម :

ក-ផលិត ឬកែច្នៃសំរាប់ដឹកជញ្ជូនទំនិញតាមផ្លូវគោក

ខ-បានចុះបញ្ជីនៅក្នុងទឹកដីនៃភាគីចុះហត្ថលេខាណាមួយ និង ជាកម្មសិទ្ធរបស់អ្នកដឹកជញ្ជូនដែលមានការអនុញ្ញាតិត្រឹមត្រូវអោយដឹកទំនិញ ។

៨- ពាក្យថា " រ៉ឺម៉ក ឬពាក់កណ្តាលរ៉ឺម៉ក " គឺជាមធ្យោបាយមួយប្រភេទ ដែលគេផលិតសំរាប់សណ្តោងដោយរថយន្តអូស ។រ៉ឺម៉ក ឬពាក់កណ្តាលរ៉ឺម៉ក ត្រូវមានលក្ខណៈដូចខាងក្រោម :

ក - ផលិតសំរាប់ដឹកជញ្ជូនទំនិញ

ខ - បានចុះបញ្ជីនៅក្នុងទឹកដីនៃភាគីចុះហត្ថលេខាណាមួយ និង ជាកម្មសិទ្ធរបស់អ្នកដឹកជញ្ជូនដែលមានការអនុញ្ញាតិត្រឹមត្រូវតាមច្បាប់អោយដឹកជញ្ជូនទំនិញ ។

គ- ការផ្គុំគ្នារវាងរថយន្តអូស និង រ៉ឺម៉ក ឬពាក់កណ្តាលរ៉ឺម៉កត្រូវចាត់ទុកជារថយន្តតែមួយ ។

## ប្រការ ៣
## សេចក្តីអនុញ្ញាតិ

១-អាជ្ញាធរមានសមត្ថកិច្ច នៃភាគីចុះហត្ថលេខានីមួយៗ ត្រូវចេញលិខិតអនុញ្ញាតិធ្វើអាជីវកម្មសំរាប់រថយន្ត ដឹ=ជញ្ជូនផ្លូវគោកនីមួយៗនៃប្រទេសរៀងខ្លួន ដើម្បីអនុវត្តការដឹកជញ្ជូនទំនិញ អ្នកដំណើរឆ្លងកាត់ព្រំដែនប្រទេសទាំងពីរ ដោយអនុលោមតាមគំរូលិខិតអនុញ្ញាតិ ដែលភាគីចុះហត្ថលេខាបានឯកភាពគ្នា ។

២-រថយន្តធ្វើអាជីវកម្មដឹកជញ្ជូន និង រថយន្តដឹកជញ្ជូនគ្មានកំរៃ ដែលបានចុះបញ្ជីនៅក្នុងទឹកដីប្រទេសកម្ពុជា ឬ ប្រទេសឡាវ ត្រូវ បានអនុញ្ញាតិឱ្យ ធ្វើចលនាទៅមក តាមច្រកទ្វារព្រំដែនដែលបានកំណត់រវាងទឹកដីនៃភាគីចុះហត្ថលេខា ទាំងពីរ ឬ ធ្វើចរាចរឆ្លងកាត់ទឹកដីនៃភាគីចុះហត្ថលេខាណាមួយ ។

## ប្រការ ៤
## ផ្លាកលេខ បណ្ណបើកបរ ច្បាប់អាជីវកម្ម ធានារ៉ាប់រង ជនទី ៣

១-រថយន្តដឹកទំនិញ និង រថយន្តដឹកអ្នកដំណើរ (រួមទាំងរថយន្តដឹកអ្នកទេសចរណ៍ ) របស់ភាគី ចុះហត្ថលេខាម្ខាង នៅពេលធ្វើអាជីវកម្មលើទឹកដីនៃភាគីចុះហត្ថលេខាម្ខាង ទៀតត្រូវ :

ក-មានពាក់ផ្លាកលេខចុះបញ្ជី ដែលចេញឱ្យដោយអាជ្ញាធរមានសមត្ថកិច្ច នៃភាគីចុះហត្ថលេខាម្ខាងទៀត ។

ខ-មានលិខិតអនុញ្ញាតិឆ្លងដែន និង មានបិទសញ្ញាពិសេស ដែលចេញឱ្យដោយអាជ្ញាធរមានសមត្ថកិច្ច នៃភាគីចុះហត្ថលេខាម្ខាងទៀត។ រូបភាពនៃលិខិតអនុញ្ញាតិឆ្លងដែន និង សញ្ញាពិសេសត្រូវមានការយល់

ព្រម និង ឯកភាពដោយអាជ្ញាធរមានសមត្ថកិច្ច នៃភាគីចុះហត្ថលេខាទាំងពីរ ។

គ-មានច្បាប់អនុញ្ញាតិធ្វើអាជីវកម្ម ដែលចេញឱ្យដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីចុះហត្ថលេខានៅក្នុងទឹកដីដែលរថយន្តបានចុះបញ្ជី ។

ឃ- មានលិខិតធានារ៉ាប់រងជនទីពី របស់ម្ចាស់រថយន្ត ។

២- " រថយន្តដឹកជញ្ជូនគ្មានកំរៃ " ត្រូវមានគ្រប់ឯកសារ ដែលមានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចទាំងពីរ ។

៣-គ្រប់អ្នកបើកបរត្រូវមានបណ្ណ័បើកបរជាតិ ឬ អន្តរជាតិ មានសុពលភាព និង សមស្របតាមប្រភេទរថយន្តដែលកំពុងបើកបរ និង មានការអនុញ្ញាតិអោយប្រើប្រាស់នៅក្នុងទឹកដីនៃភាគីម្ខាងទៀត ។

## ប្រការ ៥

## ចលនាប្រជាជន លិខិតឆ្លងដែន និងទិដ្ឋាការមានសុពលភាព

១-ចលនាឆ្លងកាត់ព្រំដែន របស់ប្រជាជនរស់នៅក្នុងតំបនជាប់ព្រំដែន នៃភាគីចុះហត្ថលេខាទាំងពីរត្រូវអនុវត្តតាមកិច្ចព្រមព្រៀងមួយដោយឡែក ។

២-អ្នកដំណើរទាំងឡាយផ្សេងទៀត រួមទាំងអ្នកបើកបរ ត្រូវមានលិខិតឆ្លងដែន ដែលមានសុពលភាព និងទិដ្ឋាកា ដែលមានតែមប្រើយ៍ត្រឹមត្រូវនៅពេលឆ្លងកាត់ព្រំដែនតាមផ្លូវគោកចូលទៅក្នុងទឹកដី នៃភាគីចុះហត្ថលេខាម្ខាងទៀត ។

៣-អ្នកបើកបរ និងជនណា ដែលត្រូវធ្វើការដឹកជញ្ជូនតាមផ្លូវគោក ដោយឆ្លងកាត់ជាញឹកញាប់ អាចប្រើប្រាស់ទិដ្ឋាកា ដែលអនុញ្ញាតឱ្យចេញចូលច្រើនដង ។

៤-បទបញ្ញត្តិ ស្តីពី ប្រភេទនៃលិខិតឆ្លងដែន និង ទិដ្ឋាការ នឹងត្រូវបានចែងដោយរដ្ឋាភិបាល នៃភាគីចុះហត្ថលេខា ។

## ប្រការ ៦

## ការបង្ហាញឯកសារ

១-លិខិតអនុញ្ញាត និង ឯកសារផ្សេងៗទៀតដែលពាក់ពន្ធ័ ទៅនឹងអ្នកដំណើរ ទំនិញ និង រថយន្តដឹកជញ្ជូន ហើយ ដែលតំរូវអោយមាន ដោយអនុលោមតាមបញ្ញាតិ នៃកិច្ចព្រមព្រៀងនេះត្រូវស្ថិតជាប់នឹងអ្នកដំណើរ ទំនិញ ឬ មធ្យោបាយដឹកជញ្ជូន និងត្រូវបង្ហាញជូនតាមការទាមទារ របស់អាជ្ញាធរមានសមត្ថកិច្ច នៃភាគីចុះហត្ថលេខាម្ខាង ។

២-ឯកសារណាមួយ ដែលពុំមានបញ្ជាក់ជាភាសាអង់គ្លេស ត្រូវមានការបកប្រែជាភាសាអង់គ្លេសដោយអាជ្ញាធរមានសមត្ថកិច្ច ។

## ប្រការ ៧
## ការហាមធ្វើអាជីវកម្មក្នុងទឹកដីតែមួយ

រថយន្តដឹកទំនិញ និង រថយន្តដឹកអ្នកដំណើរ ( រួមទាំងរថយន្តដឹកទេសចរណ៍ ) របស់ភាគីម្ខាង ពេលធ្វើអាជីវកម្ម នៅ ក្នុងទឹកដីនៃភាគីម្ខាងទៀត ត្រូវបានហាមប្រមូលទំនិញ ឬទទួលដឹកអ្នកដំណើរ ( រួមទាំងអ្នកទេសចរណ៍ ) ពីចំណុចណាមួយហើយធ្វើការដាក់ចុះ ឬ ប្រគល់នៅត្រង់ចំណុចណាមួយទៀតនៅក្នុងទឹកដីនៃភាគីម្ខាងទៀតនេះ ( លើកលែងតែមានការអនុញ្ញាតិពីរដ្ឋាភិបាល នៃភាគីចុះហត្ថលេខានោះឱ្យធ្វើអាជីវកម្មនៅក្នុងទឹកដីរបស់ខ្លួន ) ។

## ប្រការ ៨
## ការកំណត់ផ្លូវធ្វើអាជីវកម្ម និង ការប្រើប្រាស់កំពង់ផែ

១-គ្រប់មធ្យោបាយដឹកជញ្ជូន-លើកលែងតែ " រថយន្តដឹកជញ្ជូនគ្មានកំរៃ " ដែលមានចែងក្នុង ប្រការ៣ វាក្យខណ្ឌ២ -ដែលធ្វើអាជីវកម្មតាមបញ្ញត្តិ នៃកិច្ចព្រមព្រៀងនេះ ត្រូវធ្វើចរាចរតាមច្រកទ្វារព្រំដែន និង តាមផ្លូវ ដែលមានកំណត់នៅក្នុងលិខិតអនុញ្ញាតិធ្វើអាជីវកម្មដឹកជញ្ជូន ។

២-ភាគីទាំងពីរបានយល់ព្រមអនុញ្ញាត ទៅវិញទៅមក ការប្រើប្រាស់កំពង់ផែ របស់ខ្លួន "កំពង់ផែសមុទ្រ និង កំពង់ផែទន្លេ " និងការផ្ញើទំនិញក្នុងឃ្លាំង ចំពោះការដឹកជញ្ជូនតាមផ្លូវគោក ទៅមក រវាងព្រំដែននៃប្រទេសទាំងពីរ ឬឆ្លងកាត់ទឹកដីនៃភាគីចុះហត្ថលេខា ណាមួយ ។

## ប្រការ ៩
## ប្រេងឥន្ធនៈ និង សម្ភារៈសំរាប់រថយន្ត និង ការគោរពបរិស្ថាន

១-សម្ភារៈដូចតទៅនេះ ដែលត្រូវនាំចូលទៅក្នុងទឹកដី នៃភាគីចុះហត្ថលេខាម្ខាង ត្រូវប្រកាសនៅទីចាត់ការគយ និង ត្រូវអនុញ្ញាតិឱ្យរួចពន្ធនាំចេញ ឬ នាំចូល :

ក-ប្រេងឥន្ធនៈដែលផ្ទុកក្នុងធុងសាំងដែលភ្ជាប់ទៅនឹងប្រភេទរថយន្តនិមួយៗ និង រៀបចំតាមគំរោងបច្ចេកទេស និង តាមគំរូផលិតជាលក្ខណៈអន្តរជាតិ ។

ខ-ប្រេងរំអិលដែលមានចំនួនចាំបាច់ សំរាប់ប្រើប្រាស់នៅពេលធ្វើអាជីវកម្ម ។

គ-គ្រឿងបន្លាស់ និង សម្ភារៈសំរាប់រថយន្ត ។

ឃ-គ្រឿងបន្លាស់ ឬ ដុំដែលដោះចេញពីរថយន្ត ដោយសារខូចប្រើការលែងកើត ហើយ ត្រូវយកត្រឡប់ទៅប្រទេសដើមវិញ ។

២-រថយន្តដឹកជញ្ជូនតាមផ្លូវគោកនៃភាគីនិមួយៗ នៅពេលដឹកជញ្ជូនអ្នកដំណើរ ឬ ទំនិញនៅក្នុងទឹកដី នៃភាគីម្ខាងទៀត មិនត្រូវទុកចោលវត្ថុទាំងឡាយណា ដែលអាចធ្វើឱ្យខូចបរិស្ថាន នៃភាគីនេះឡើយ ។

## ប្រការ ១០

## អាទិភាព នៃ ការបំពេញបែបបទគយ

អាទិភាពនៃការបំពេញបែបបទគយ នៅពេលឆ្លងកាត់ព្រំដែនរវាងទឹកដីនៃភាគីចុះហត្ថលេខាទាំងពីរត្រូវអនុវត្តតាមលំដាប់លំដោយដូចខាងក្រោម:

ក- **អាទិភាព ទី១ :** ការដឹកជញ្ជូនអ្នកជំងឺធ្ងន់-អ្នកទេសចរណ៍ - អ្នកដំណើរ-សាកសព

ខ- **អាទិភាព ទី២ :** ការដឹកជញ្ជូនសត្វពាហនៈ ការដឹកជញ្ជូនដឹកទំនិញងាយខូច បន្លែស្រស់

គ- **អាទិភាព ទី៣ :** ការដឹកជញ្ជូនទំនិញមានគ្រោះថ្នាក់ ។

## ប្រការ ១១

## ពន្ធឆ្លងកាត់ ‐ ចំណាយផ្សេងៗ

ម្ចាស់រថយន្តធ្វើអាជីវកម្មដឹកជញ្ជូន និង " រថយន្តដឹកជញ្ជូនគ្មានកំរៃ" ដែលបានចុះបញ្ជីក្នុងទឹកដី នៃភាគីម្ខាង នៅពេលចូលទៅក្នុងទឹកដី នៃភាគីម្ខាងទៀត ត្រូវបង់ពន្ធឆ្លងកាត់ និង បន្ទុកចំណាយផ្សេងៗដូចជា យន្តបទ ស្ពានសាឡាង ជាដើម ។ គ្រប់ពន្ធឆ្លងកាត់ និង បន្ទុកចំណាយផ្សេងៗត្រូវកំណត់ដោយ អាជ្ញាធរមានសមត្ថកិច្ច នៃ ភាគីចុះហត្ថលេខានីមួយៗ ដោយមានការពិគ្រោះយោបល់គ្នាទៅវិញទៅមក ។

## ប្រការ ១២

## ការអនុវត្តតាមច្បាប់របស់ប្រទេស

១-អ្នកដឹកជញ្ជូនទាំងឡាយណា ដែលបានទទួលការអនុញ្ញាតិអោយប្រកបសេវាដឹកជញ្ជូន ដោយប្រើប្រាស់រថយន្តដឹកជញ្ជូនអ្នកដំណើរ និង រថយន្តដឹកទំនិញទៅមករវាងទឹកដី នៃភាគីចុះហត្ថលេខាទាំងពីរ ឬ ឆ្លងកាត់ទឹកដី នៃភាគីចុះហត្ថលេខាណាមួយ ត្រូវអនុវត្តតាមច្បាប់ និង បទបញ្ញាតិជាតិជាធរមាននៅក្នុងទឹកដីនេះ ។

២-រថយន្តដឹកជញ្ជូនគ្មានកំរៃ រថយន្តដឹកអ្នកដំណើរ ( រួមទាំងរថយន្តដឹកអ្នកទេសចរណ៍ និងរថយន្តដឹកទំនិញរបស់ភាគីចុះហត្ថលេខាម្ខាង នៅពេលចូលទៅទឹកដី នៃភាគីចុះហត្ថលេខាម្ខាងទៀត ត្រូវអនុវត្តតាមច្បាប់ និង បទបញ្ញតិ ជាធរមាន នៅក្នុងទឹកដីនេះ ។

## ប្រការ ១៣

## ឧបទ្ទវហេតុ គ្រោះថ្នាក់

ក្នុងករណីមធ្យោបាយដឹកជញ្ជូនរបស់ភាគីចុះហត្ថលេខាម្ខាង ត្រូវទទួលរងនូវគ្រោះថ្នាក់ ឬ មានឧបទ្ទវហេតុអ្វីមួយ នៅពេលធ្វើអាជីវកម្មក្នុងទឹកដីភាគីចុះហត្ថលេខាម្ខាងទៀត អាជ្ញាធរមានសមត្ថកិច្ចនៅកន្លែងកើតហេតុ ត្រូវដោះស្រាយឧបទ្ទវហេតុ ឬ គ្រោះថ្នាក់នោះទៅតាមច្បាប់ប្រទេសរបស់ខ្លួន ហើយត្រូវរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីចុះហត្ថលេខាជាម្ចាស់មធ្យោបាយអំពីវិធានការ និង ដំណោះស្រាយដែលខ្លួនបានចាត់ចែងរួចហើយ ឱ្យបាន-ឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។

## ប្រការ ១៤

## ការដោះស្រាយទំនាស់

១-នៅពេលកំពុងអនុវត្តកិច្ចព្រមព្រៀង ទំនាស់ទាំងឡាយណាដែលកើតឡើងដោយសារ ការអនុវត្តខុសពីកិច្ចព្រមព្រៀង ឬការបកស្រាយកិច្ចព្រមព្រៀងខុស អាជ្ញាធរមានសមត្ថកិច្ច នៃភាគីហត្ថលេខាទាំងពីរ ត្រូវដោះស្រាយទំនាស់នេះ ដោយការចរចារគ្នា ។

២-រាល់ទំនាស់ ដែលកើតឡើងរវាងអាជីវករ និងបុគ្គលពាក់ពន្ធ័ផ្សេងទៀត ទាក់ទងទៅនឹងការអនុវត្តកិច្ចសន្យាដឹកជញ្ជូន ទំនាស់នោះត្រូវដោះស្រាយ ដោយអាជីវករខ្លួនឯងដោយការចរចារគ្នា។ ក្នុងករណីពុំឯកភាពគ្នា ទំនាស់នេះត្រូវដោះស្រាយតាមច្បាប់ និង បទបញ្ញត្តិ ជាធរមាននៅលើទឹកដីនៃភាគីចុះហត្ថលេខាដែលទំនាស់នេះកើតឡើង ហើយនៅទីបញ្ចប់ បើនៅតែពុំមានការឯកភាពគ្នា ទៀតនោះ ត្រូវដោះស្រាយតាមអាជ្ញាកណ្តាលអន្តរជាតិ ដែលអ្នកដឹកជញ្ជូននិងបុគ្គលពាក់ពន្ធ័បានឯកភាពគ្នា ។

## ប្រការ ១៥

## ការសើរើ ~ វិសោធនកម្ម

១-នៅពេលកំពុងអនុវត្តកិច្ចព្រមព្រៀងនេះ ភាគីចុះហត្ថលេខាណាមួយអាចស្នើជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀតឱ្យមានការសើរើ ឬ ធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀងនេះ ។ ភាគីចុះហត្ថលេខាម្ខាងទៀត ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរ ចំពោះសំណើនេះវិញ ក្នុងពេល ៣០ ថ្ងៃ គិតចាប់តាំងពីថ្ងៃដែលបានទទួលសំណើនេះ ។

២-បញ្ញត្តិទាំងឡាយដែលបានធ្វើការសើរើ ឬ ធ្វើវិសោធនកម្ម ដោយមានការឯកភាពគ្នា ទាំងសងខាងនោះត្រូវមានប្រសិទ្ធភាពចាប់តាំងពីថ្ងៃ ដែលមានការប្រគល់លិខិតយល់ព្រមទៅវិញទៅមកនិងត្រូវចាត់ទុកថាជាចំណែកមួយស្របច្បាប់ទាំងស្រុង នៃកិច្ចព្រមព្រៀងនេះ ។

## ប្រការ ១៦
## ប្រសិទ្ធិភាពនៃសន្ធិសញ្ញាដែលមានស្រាប់

បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ មិនប៉ះពាល់ផលប្រយោជន៍ និង កាតព្វកិច្ច របស់ភាគីចុះហត្ថលេខានីមួយៗ ដែលមានចែងយ៉ាងច្បាស់នៅក្នុង សិទ្ធិសញ្ញាអន្តរជាតិដែលមានស្រាប់ ហើយដែលភាគីណាមួយបានចុះហត្ថលេខារួចហើយនោះ ។

## ប្រការ ១៧
## ការមិនអនុវត្តន៍ចំពោះមធ្យោបាយដឹកជញ្ជូនរបស់ប្រទេសទី៣

កិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តចំពោះមធ្យោបាយដឹកជញ្ជូនផ្លូវគោកណា ដែលបានចុះបញ្ជីនៅប្រទេសទី ៣ ហើយ ប្រើប្រាស់ផ្លូវរបស់ភាគីចុះហត្ថលេខាម្ខាង ដើម្បីចូលទៅក្នុងទឹកដីនៃភាគីចុះហត្ថលេខាម្ខាងទៀត និងមិនអនុវត្តចំពោះ ការចូលរួមនៃមធ្យោបាយដឹកជញ្ជូនផ្លូវគោកណាដែលចុះបញ្ជីនៅប្រទេសទី ៣ ក្នុងការដឹកជញ្ជូនទំនិញ អ្នកដំណើរនៃ ភាគីចុះហត្ថលេខាម្ខាងចូលទៅក្នុងទឹកដីនៃភាគីចុះហត្ថលេខាម្ខាងទៀតឡើយ ។ លើកលែងតែមធ្យោបាយដឹកជញ្ជូនរបស់ប្រទេសទី៣ ដែលបានចុះកិច្ចព្រមព្រៀង លើការដឹកជញ្ជូនតាមផ្លូវគោក ជាមួយនឹងភាគីចុះហត្ថលេខាទាំងពីរ ។

## ប្រការ ១៨
## អង្គភាពអនុវត្តកិច្ចព្រមព្រៀង

១-រដ្ឋាភិបាលនៃភាគីចុះហត្ថលេខាទាំងពីរ ប្រគល់ភារកិច្ចឱ្យក្រសួងសាធារណការ និង ដឹកជញ្ជូន នៃប្រទេសកម្ពុជា និងក្រសួងគមនាគមន៍ដឹកជញ្ជូនប្រៃសណីយ៍ និង សំណង់ នៃ ប្រទេសឡាវ រៀបចំតាក់តែងបែបបទលំអិតនៅក្នុងពិធីសារ ដើម្បីអនុវត្តកិច្ចព្រមព្រៀងដឹកជញ្ជូនផ្លូវគោកនេះ ។

២-ក្រសួងសាធារណការ និង ដឹកជញ្ជូនរបស់ប្រទេសកម្ពុជា និង ក្រសួងគមនាគមន៍ដឹកជញ្ជូនប្រៃសណីយ៍ និងសំណង់របស់ប្រទេសឡាវ ត្រូវប្រគល់ ភារកិច្ចឱ្យអង្គភាពណាមួយទទួលខុសត្រូវធ្វើ ការណែនាំ ត្រួតពិនិត្យការអនុវត្តកិច្ចព្រមព្រៀង ចេញលិខិតអនុញ្ញាតិធ្វើ អាជីវកម្ម ចំពោះរថយន្តដែលចែងក្នុងកិច្ចព្រមព្រៀងនេះ និង ដោះស្រាយរាល់រឿងរ៉ាវដែលកើតមាន នៅពេលកំពុងអនុវត្តកិច្ចព្រមព្រៀងនេះ ។

# ប្រការ ១៩

## ការចូលជាធរមាន និង សុពលភាព

១-កិច្ចព្រមព្រៀងនេះត្រូវចូលជាធរមាននៅរយៈពេល ៣០ ថ្ងៃ ក្រោយដែលភាគីទាំងពីរបានប្រគល់ទទួលលិខិតយល់ព្រមទៅវិញទៅមករួចហើយ ។

២-បន្ទាប់មក កិច្ចព្រមព្រៀងនេះត្រូវមានសុពលភាពសារជាថ្មីជាស្វ័យប្រវត្តិ សំរាប់រយៈពេលមួយឆ្នាំម្តង លើកលែង តែកិច្ចព្រមព្រៀងនេះត្រូវបានបញ្ចប់ដោយភាគីចុះហត្ថលេខាម្ខាង ដោយផ្ញើទៅភាគីចុះហត្ថលេខា ម្ខាងទៀតតាមផ្លូវការទូតនូវសេចក្តីប្រកាសជាលាយលក្ខណ៍អក្សរ អំពីការស្នើបញ្ចប់កិច្ចព្រមព្រៀងក្នុងរយៈពេលបីខែមុនពេលដែលសុពលភាពត្រូវចាប់ផ្តើមសារជាថ្មី ជាស្វ័យប្រវត្តិ ។

៣-កិច្ចព្រមព្រៀងនេះអាចបញ្ចប់នៅមុនពេលអស់សុពលភាព បើសិនជាភាគីចុះហត្ថលេខាម្ខាងបានប្រកាសបញ្ជាក់ជាលាយលក្ខណ៍អក្សរ តាមផ្លូវការទូតទៅភាគីចុះហត្ថលេខាម្ខាងទៀត អំពីសំណើសុំបញ្ចប់ កិច្ចព្រមព្រៀងនេះ ។ ហើយកិច្ចព្រមព្រៀងត្រូវអស់សុពលភាពក្នុងរយៈពេលប្រាំមួយខែ ក្រោយពីថ្ងៃដែលភាគីចុះហត្ថលេខាម្ខាងទៀត ប្រកាសថាបានទទួលលិខិតស្នើសុំនេះ ។

**ដើម្បីជាសក្ខីភាព** ហត្ថលេខីខាងក្រោម ដែល បានទទួលការសិទ្ធប្រទានឱ្យចុះហត្ថលេខាយ៉ាងត្រឹមត្រូវ ពីរដ្ឋាភិបាលរៀង១ខ្លួន បានចុះហត្ថលេខាលើកិច្ចប្រមព្រៀងរវាង រដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាល នៃ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ស្តីការដឹកជញ្ជូនតាមផ្លូវគោក ។

**ធ្វើនៅ វៀងចន្ទ**, នៅថ្ងៃទី ២១ ខែតុលា ឆ្នាំ ១៩៩៩ ជាពីរច្បាប់ដើម ជា ភាសាខ្មែរ ឡាវ និង អង់គ្លេស។ ច្បាប់នីមួយ១មានតម្លៃស្មើគ្នា។ ក្នុងករណីមានការបកស្រាយខុសគ្នា ភាសាអង់គ្លេសត្រូវយកមកប្រើប្រាស់ជាគោល ។

| | |
|---|---|
| **តំណាងរដ្ឋាភិបាល** | **តំណាងរដ្ឋាភិបាល** |
| **ព្រះរាជាណាចក្រកម្ពុជា** | **សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ** |
| **ឯកឧត្តម ឃី តាំង លីម** | **ឯកឧត្តម ផាវ ប៊ុណ្ណាផុន** |
| **រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន** | **រដ្ឋមន្ត្រីក្រសួងគមនាគមន៍ដឹកជញ្ជូន ប្រៃសណីយ៍ និងសំណង់** |